# រឿង មហាចោរនៅទល់ដែន

**ភាគទី៦២** (ក្បួនការពារឯករាជ្យ)

រីឯអ្នកវាយក៏ធ្វើជាវាត់ទាត់ជាក់ឥតត្រាប្រណី។ បដាមួយធ្វើអំពីសំពត់ល្អស្អាត មានសរសេរពាក្យថា “ត្រូវតែគោរពសាសនា”។ នៅលើឆាកល្ខោនខាងក្រោយទៀត គេលេងរឿងពួកឧទ្ទាមកំពុងធ្វើបាបអ្នកស្រុក ដែលសំពះអង្វរស្រែកឲ្យព្រះកម្ពុត និងព្រះនាងមណីជួយ។ បដានៃវង្សល្ខោននេះមានចំណងជើងថា “សៀមនិងខ្មែរជាបងប្អូននឹងគ្នា”។ នៅជិតបដានេះមានបដាមួយធំគូររូបស្ដេចមានដាក់អក្សរថា “ត្រូវតែគោរពព្រះមហាក្សត្រីយ៍ក្រុងអយុធ្យាយើង”។

បន្ទាប់ពីវង់ល្ខោនដ៏ចម្លែកនោះ គង់លើខ្នងដំរីមួយ នារីម្នាក់តែងខ្លួនជាព្រះនាងខត្តិយាណីកែវមណីកំពុងបាចទានដល់អ្នកស្រុក។ នៅជុំវិញស្ត្រីដ៏ឧត្តមមានអ្នកសុំទាន អ្នកក្រីក្រ និងក្មេងៗដែលប្រជែងគ្នាចាំរើសទាន។

នៅចុងក្រោយបង្អស់ឆ្ងាយដាច់ពីគេមានរទេះមួយ។ ក្នុងរទេះនេះ ព្រះនាងមណីអង្គុយជិតស្រីម្នាក់នៅក្មេងរូបស្អាត គឺនាងមាលាបុត្រីរបស់ពូឧត្តុង្គដែលយើងធ្លាប់បានឃើញមកហើយ។

នាងមាលាក្រោយពីពេលដែលបានជួយរំដោះឲ្យមានន្ទរត់ បានចូលខ្លួនធ្វើជាអ្នកបម្រើព្រះកម្ពុត។ នាងខិតខំធ្វើការ ត្រាតែព្រះនាងមណីស្រលាញ់ពេញចិត្ត ហៅមកនៅជាមួយឲ្យធ្វើជាស្នំឯករបស់នាង។ កិច្ចការអ្វីផ្សេងៗ នាងមាលាដឹងឥតខ្វះឡើយ។

សងខាងរទេះ មានអ្នកជិះសេះបួននាក់: កាមា និលពេជ្រ និលឯក មហារន្ទះ ដែលសុទ្ធជាសេនាជំនិតរបស់ស្ត្រីធីតា “មណី”។

ក្នុងរាជរថដែលរំលេចក្បាច់ និងពណ៌ឆើតឆាយនេះ ព្រះនាងមានព្រះភ័ក្ត្រក្រៀមក្រំ។ នេត្រាស្រីរលោងដូចកែវមរកត។ ក្នុងរស្មីនេត្រានេះគេអាចឃើញបានថា ព្រះនាងកំពុងគិត។

នាងមាលាពុំហ៊ានកម្រើកខ្លួនឡើយ។ មាណវីចង់ដឹងនូវទុក្ខរបស់នាងខត្តិយាណីណាស់។ លំដាប់នោះព្រះនាងបើកកន្ត្រកស្បែកមួយ ហូតយកកូនកន្សែងមកជូតមុខញើសសំបោរនាងមាលាភ័យ ព្រោះនាងសង្កេតឃើញថាព្រះនាងយំ។

ស្រីជាទាសីក៏ដាច់ចិត្តសួរយ៉ាងស្លូតត្រង់ថា:

អ្នកបងមានរឿងអ្វី? សូមអាណិតប្រាប់ខ្ញុំផង!

អត្ថបទដោយ៖ មាស សុភាព

នាងមណីនៅស្ងៀម មើលមុខនាងមាលា។ សេចក្តីអាណិតមួយរត់ចាបដួងចិត្តជីតា ត្បិតភ្នែកនាងទាសីក៏ឡើងរលីងរលោងដែរ។

ស្រីក៏ឆ្លើយយ៉ាងស្រងូតស្រងាត់ថា:

បងព្រួយចិត្តណាស់អូន អូនឯងស្រលាញ់បងទេ?

នាងមាលាឱនមុខសញ្ជឹងគិត រួចឆ្លើយតិចៗថា:

ការនេះស្រេចលើអ្នកបងចុះ។ ប្អូនបានមកនៅជាមួយអ្នកបងយូរណាស់ទៅហើយ គឺជិតមួយឆ្នាំហើយ អ្នកបងក៏ដឹងចិត្ត ស្គាល់ចិត្តខ្ញុំអស់ហើយ។

កែវមណីញញឹមទាំងទឹកភ្នែក:

អឺ! បងសង្កេតឃើញថា ប្អូនស្រលាញ់បងមែន! ឯបងក៏ស្រលាញ់ប្អូនណាស់ដែរ តែថ្ងៃនេះបងព្រួយចិត្ត បងសឹងតែត្រូវការមនុស្សម្នាក់ ដើម្បីនិយាយគ្នាលេងអោយបានធូរដើមទ្រូងបន្តិចៗ បងចង់និយាយនឹងមនុស្សណាម្នាក់ដែលស្រលាញ់បង។ បងខំរិះរកមនុស្សនោះ មិនឃើញសោះ។ ឱ! បើមនុស្សនោះ ជាភេទខុសគ្នាវិញ ម៉្លោះសមពេញចិត្តយ៉ាងណាទេ!

នាងមាលាបើកភ្នែកធំ តែមិនហ៊ាននិយាយអ្វីឡើយ។ នាងខំប្រឹងសម្រួលទឹកមុខឱ្យបានស្រួលដែរ តែពាក្យព្រះនាងហាក់ខុសប្លែកធម្មតាពេក។ ធម្មតានាងមាលាសង្កេតឃើញថា ព្រះនាងមានចិត្តរឹងប៉ឹងណាស់និយាយតែពីកិច្ចការ។ ចុះចម្លែកអ្វីម៉្លេះ ថ្ងៃនេះព្រះនាងធ្លាក់មកនៅត្រឹមស្រីសាមញ្ញម្នាក់ទៅវិញ ដែលចេះស្រលាញ់នោះ? នាងមាលានឹកឃើញភ្លាម ក៏និយាយទាំងប្រញាប់ថា:

ចុះបងកាមា?

នាងមណីសើច ងក់ក្បាល រួចគ្រវីក្បាលវិញ:

ទេ! ប្អូនប៉ាន់នេះមិនត្រូវទេ! មើលប្អូនប្អូនប៉ាន់ទៀតមើល៍?

នាងមាលាសើចម្តងវិញ រួចសប្បាយជាពន្លឹក ព្រោះពេលនេះនាងដឹងមនោសញ្ចេតនាប្រាកដរបស់ស្រីជាចៅហ្វាយ។

ខ្ញុំមិនដឹងឈ្មោះបុរសណាទេ ពីព្រោះប្រហែលជាបុរសនោះសព្វថ្ងៃនៅឆ្ងាយហើយមើលទៅ!

នាងមណីចាប់ដៃនាងមាលាជាប់។

ចាំះ! ចាំះ! អូនកុំនិយាយទៀត។

អត្ថបទដោយ៖ មាស សុភាព

*នាងមាលាឃើញថា ដៃនេះត្រជាក់ហើយញ័រៗបន្តិចផង ដែលជាហេតុធ្វើឲ្យនាងឆ្ងល់កាន់ តែខ្លាំងទៅទៀត។ នាងនឹកឃ្លាដើមឃើញថាស្រីវរលក្ខណ៍មានសង្សារ។ សង្សារនោះទៅឆ្ងាយតែធ្វើម្ដេចឲ្យស្គាល់ឈ្មោះទៀត? នាងមាលាក៏និយាយដោយកិច្ចឧបាយថា:*

*ខ្ញុំស្ដាយណាស់ដោយមិនដឹងឈ្មោះបុរសនោះ។*

*ព្រះនាងមានបបូរមាត់ឡើងស្វាំង បែបជាភ័យផងអៀនផង។ ពីតាក៏បែរខ្នងដាក់សញ្ញាជាស្នំគាប់ចិត្ត រួចពោលវាចារយ៉ាងស្រងូតស្រងាត់អស់ពីពោះថា:*

*ចាំះ! ចាំះ! គេនៅឆ្ងាយ! ឆ្ងាយរកខ្ញុំទៅមិនដល់ចាប់មិនបាន! គឺបង...បង....បងមានន្ទ!!*

*នាងមណីព្រឺខ្នងខ្វាកៗ ដោយបានដំណឹងដ៏អស្ចារ្យនេះ ទឹកមុខនាងក៏ឡើងស្លេកស្វាំងដែរ។ ចុងដៃចុងជើងនាងឡើងត្រជាក់ដែរ។ នាងឮសំដីព្រះនាងកាន់តែតិចទៅៗទៀតថា:*

*ឥឡូវបងនៅសល់តែអនុស្សាវរីយ៍បងមានន្ទទេ!*

*ថាតែប៉ុណ្ណោះព្រះនាងព្រះទៅក្រោយលើពូកដ៏ល្អស្អាត បង្ហាញថាស្រីឆ្នើមរវើយអស់កម្លាំងរលីងពីខ្លួនហើយ។*

*នាងមាលាក៏ស្ទើរដួលដូចនាងទៀត។ ម្ដងនេះ ស្រាប់តែព្រះនាងក្រោកអង្គុយត្រង់ខ្លួនវិញ សើចទាំងទឹកមុខក្រៀមក្រំរួចនិយាយច្បាស់ៗ ខាំធ្មេញដូចតទៅ:*

**(សូមរង់ចាំតាមដានភាគទី៦៣ នៅសប្ដាហ៍ក្រោយ)**

KHMER CIVILIZATION

*អត្ថបទដោយ៖ មាស សុភាព*